ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 11

# កិច្ចសន្យាសាងសង់

## Construction Contracts

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# **អារម្ភកថា**

ដោយសារនយោបាយ **“ឈ្នះ-ឈ្នះ”** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា **“យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣”**, **“ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨”**, **“យុទ្ធសាស្ត្រត្រីកោណ”**, **“យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០”** និង **“យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨”** ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអាទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី **“ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ”** ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ពន្ធ័ទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ពន្ធ័នៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ចឺ តាយី**

## គោលដៅ

គោលដៅនៃស្តង់ដានេះ កំណត់នូវការកត់ត្រាគណនេយ្យនៃចំណូល និងថ្លៃដើមដែលកើតពីកិច្ចន្យាសាងសង់ ។ ដោយសារតែចរិកលក្ខណៈនៃសកម្មភាពដែលបានធ្វើឡើងតាមកិច្ចសន្យាសាងសង់ នាំឱ្យកាលបរិច្ឆេទដែលសកម្មភាពក្នុងកិច្ចសន្យាបានធ្វើឡើង និងកាលបរិច្ឆេទនៅពេលដែលសកម្មភាពត្រូវបានបំពេញចប់ ជាធម្មតាវាស្ថិតក្នុងការិយបរិច្ឆេទគណនេយ្យផ្សេងគ្នា ។ ដូចនេះបញ្ហាដំបូងនៃការកត់ត្រាគណនេយ្យសម្រាប់កិច្ចសន្យាសាងសង់ គឺជាការវិភាជន៍នូវចំណូល និងចំណាយថ្លៃដើមតាមកិច្ចសន្យាទៅក្នុងការិយបរិច្ឆេទគណនេយ្យ ដែលការងារសាងសង់ត្រូវបានបំពេញ ។ ស្តង់ដានេះ ប្រើលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ដែលបានបង្កើតឡើងនៅក្នុង *ក្របខណ្ឌស្តង់ដាសម្រាប់រៀបចំនិងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* * ដើម្បីកំណត់ថាពេលណាដែលចំណូល និងចំណាយថ្លៃដើមតាមកិច្ចសន្យាត្រូវបានទទួលស្គាល់ជាចំណូលនិងចំណាយនៅក្នុងរបាយការណ៍ ស្តីពីចំណូលបន្ទាប់បន្សំ ។ ស្តង់ដាក៏បានផ្តល់ផងដែរនូវគោលការណ៍សម្រាប់អនុវត្តលក្ខណៈវិនិច្ឆ័យទាំងនោះ។

## វិសាលភាព

១ ស្តង់ដានេះ ត្រូវបានប្រើប្រាស់សម្រាប់កត់ត្រាគណនេយ្យសម្រាប់កិច្ចសន្យាសាងសាង់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកសាងសង់ (អ្នកម៉ៅការ)។

២ ស្តង់ដានេះ ជំនួស ស្តង់ដាលេខ ១១ ស្តីពី *ការកត់ត្រាគណនេយ្យសម្រាប់កិច្ចសន្យាសាងសង់* ដែលបានអនុម័តក្នុងឆ្នាំ ១៩៧៨។

៣ អត្ថន័យជាក់លាក់នៃវាក្យស័ព្ទនានាដែលត្រូវបានប្រើប្រាស់នៅក្នុងស្តង់ដារនេះ មានដូចខាងក្រោម :

***កិច្ចសន្យាសាងសង់*** គឺជាកិច្ចសន្យាមួយដែលបានចរចារជាពិសេសសម្រាប់ធ្វើការសាងសង់ទ្រព្យសកម្មមួយ ឬបណ្តុំនៃទ្រព្យសកម្មនានាដែលប្លង់បច្ចេកវិទ្យានិងតួនាទី ឬគោលបំណងឬការប្រើប្រាស់ចុងក្រោយរបស់វាមានទាក់ទងឬមានភាពចំណុះគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ។

***កិច្ចសន្យាដែលមានថ្លៃថេរ*** គឺជាកិច្ចសន្យាសាងសង់មួយ ដែលអ្នកសាងសង់យល់ព្រមចំពោះកិច្ចសន្យាមួយដែលមានតម្លៃថេរ ឬយល់ព្រមចំពោះអត្រាថ្លៃថេរក្នុងមួយឯកតានៃទិន្នផលសំណង់ដែលពេលខ្លះវាជាកម្មវត្ថុនៃការចែងអំពីខ នៃការបង្កើនថ្លៃ។

***កិច្ចសន្យាបន្ថែមថ្លៃដើម*** គឺជាកិច្ចសន្យាសាងសង់មួយដែលអ្នកសាងសង់ត្រូវបានសងមកវិញនូវ ចំនួនទឹកប្រាក់តាមថ្លៃដើមបានកំណត់ ឬត្រូវបានអនុញ្ញាតបូកបន្ថែមជាមួយនឹងភាគរយនៃថ្លៃដើមទាំងនេះឬថ្លៃឈ្នួលថេរ ។

៤ កិច្ចសន្យាសាងសង់មួយ អាចត្រូវបានចរចារសម្រាប់ការសាងសង់ទ្រព្យសកម្មតែមួយ ដូចជា ស្ពាន អគារ ទំនប់ទឹក បំពង់នាំប្រេង ផ្លូវ កប៉ាល់ ឬផ្លូវរូងក្រោមដី ។ កិច្ចសន្យាសាងសង់ក៏អាចត្រូវបានធ្វើឡើង ដើម្បីសាងសង់ទ្រព្យសកម្មមួយចំនួនដែលប្លង់បច្ចេកវិទ្យានិងតួនាទី ឬគោលបំណងឬការប្រើប្រាស់ចុងក្រោយរបស់វាមានទាក់ទង ឬ មានភាពចំណុះគ្នាទៅវិញទៅមកយ៉ាង ជិតស្និទ្ធឧទាហរណ៍ដូចជាកិច្ចសន្យាដែលបញ្ចូលនូវប្លង់បច្ចេកវិទ្យា និងតួនាទី ឬគោលបំណងឬការប្រើប្រាស់ចុងក្រោយសម្រាប់ការសាងសង់ រោងចក្រស្លប្រេងកាតឬបំប្លែងនិងផ្នែកនៃអគាររបស់រោងចក្រជាដើម។

៥ សម្រាប់គោលបំណងនៃស្តង់ដារនេះកិច្ចសន្យាសាងសង់ត្រូវបញ្ចូលនូវៈ

(ក) កិច្ចសន្យាជួលសេវាកម្ម ដែលមានការទាក់ទិនផ្ទាល់ជាមួយការសាងសង់ទ្រព្យសកម្មឧទាហរណ៍ដូចជាការផ្តល់សេវាជាអ្នកគ្រប់គ្រងគម្រោងនិងស្ថាបត្យករនិង

(ខ) កិច្ចសន្យាក្នុងការបំផ្លាញ ឬស្ថាបនាឡើងវិញនូវទ្រព្យសកម្ម និងការស្ថាបនាឡើងវិញនិងបរិដ្ឋាន ដោយធ្វើទៅតាមការបំផ្លាញចោលនូវទ្រព្យសកម្ម។

៦ សម្រាប់គោលបំណងនៃស្តង់ដារនេះ កិច្ចសន្យាសាងសង់ អាចត្រូវបានធ្វើឡើងតាមមធ្យោបាយជាច្រើន ដែលត្រូវបានចាត់ជាកិច្ចសន្យាដែលមានថ្លៃថេរនិងកិច្ចសន្យាដែលមានថ្លៃបន្ថែម ។ កិច្ចសន្យាសាងសង់មួយចំនួនអាចមានចរិកលក្ខណៈជាកិច្ចសន្យាថ្លៃថេរផងនិងជាកិច្ចសន្យាមានថ្លៃបន្ថែមផងឧទាហរណ៍ដូចជាក្នុងករណីដែលមានកិច្ចសន្យាមានថ្លៃថែមមួយដែលមានថ្លៃអតិប្បរមាតាមការព្រមព្រៀង ។ ក្នុងករណីបែបនេះអ្នកសាងសង់ ត្រូវការធ្វើការពិចារណាលើលក្ខខណ្ឌទាំងអស់ក្នុងកថាខណ្ឌ ២៣ និង ២៤ ដើម្បីកំណត់ថាតើពេលណាដែលត្រូវទទួលស្គាល់ចំណូលនិងចំណាយតាមកិច្ចសន្យា ។

## ការច្របាច់បញ្ចូល និងការបែងចែកជាចំណែកនៃកិច្ចសន្យាសាងសង់

៧ ការតម្រូវរបស់ស្តង់ដារនេះ ជាធម្មតាត្រូវបានអនុវត្តដាច់ដោយឡែកចំពោះកិច្ចសន្យាផ្សេងៗគ្នា ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក្នុងកាលទេសៈមួយចំនួន វាមានការចាំបាច់ដើម្បីអនុវត្តស្តង់ដារលើសមាសមួយៗ ដែលអាចកំណត់ដាច់ដោយឡែកនៃកិច្ចសន្យាតែមួយបាន ឬលើក្រុមនៃកិច្ចសន្យាតែម្តងដើម្បីបង្ហាញអំពីសារជាតិនៃកិច្ចសន្យាឬក្រុមនៃកិច្ចសន្យា ។

៨ នៅពេលដែលកិច្ចសន្យាមួយ គ្របដណ្តប់លើទ្រព្យសកម្មមួយចំនួនផ្សេងៗគ្នា ការសាងសង់នៃទ្រព្យសកម្មនិមួយៗ ត្រូវបានចាត់ទុកថាជាកិច្ចសន្យាសាងសង់ដាច់ដោយឡែកនៅពេលដែល :

(ក) សំណើដាច់ដោយឡែកត្រូវបានដាក់ស្នើឡើងសម្រាប់ទ្រព្យសកម្មនីមួយៗ ។

(ខ) ទ្រព្យសកម្មនីមួយៗគឺជាកម្មវត្ថុនៃការចរចារដាច់ដោយឡែក ហើយអ្នកសាងសង់និងអតិថិជន មានលទ្ធភាពក្នុងការទទួលយកឬច្រានចោលនូវផ្នែកណាមួយនៃកិច្ចសន្យាទាក់ទិន នឹងទ្រព្យសកម្មនីមួយៗ និង

(ច) អាចកំណត់បាននូវថ្លៃដើមនិងចំណូលនៃទ្រព្យសកម្មនីមួយៗ។

៩ កិច្ចសន្យាមួយក្រុម ទោះបីជាកិច្ចសន្យានោះ មានអតិថិជនមានតែម្នាក់ ឬច្រើនក៏ដោយ ត្រូវតែចាត់ទុថាជាកិច្ចសន្យាសាងសង់តែមួយ នៅពេលដែល:

(ក) កិច្ចសន្យាមួយក្រុមនោះ ត្រូវបានចរចារជាកញ្ចប់ ។

(ខ) តាមពិត កិច្ចសន្យាទាំងនោះមានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ដែលជាផ្នែកមួយនៃគម្រោងតែមួយ ដែលមានកម្រិតនៃប្រាក់ចំណេញជារួមនិង

(គ) កិច្ចសន្យាត្រូវបានបំពេញដំណាលគ្នា ឬបំពេញតាមលំដាប់លំដោយបន្តបន្ទាប់។

១០ កិច្ចសន្យាអាចធ្វើឡើងសម្រាប់ការសាងសង់ទ្រព្យសកម្មបន្ថែមទៅតាមជម្រើសរបស់អតិថិជន ឬអាចត្រូវបានធ្វើវិសោធនកម្ម ដើម្បីបញ្ចូលនូវការសាងសង់ទ្រព្យសកម្មបន្ថែម ។ ការសាងសង់នូវទ្រព្យសកម្មបន្ថែមនឹងត្រូវបានចាត់ទុកថាជាកិច្ចសន្យាសាងសង់ដាច់ដោយឡែកនៅពេលដែល:

(ក) ទ្រព្យសកម្មមានភាពខុសគ្នាយ៉ាងខ្លាំងលើការរចនាបច្ចេកវិទ្យា ឬតួនាទីរបស់ទ្រព្យសកម្ម ឬទ្រព្យសកម្មដែលគ្របដណ្តប់ដោយកិច្ចសន្យាដើម ឬ

(ខ) ថ្លៃសន្ទិធិ អាចត្រូវបានចរចារ ដោយមិនគិតអំពីថ្លៃកិច្ចសន្យាដើមនោះទេ ។

## ចំណូលពីកិច្ចសន្យា

១១ ចំណូលពីកិច្ចសន្យា ត្រូវតែមាន :

(ក) ចំនួនទឹកប្រាក់ដើមដំបូងនៃចំណូលដែលបានឯកភាពយល់ព្រមក្នុងកិច្ចសន្យា និង

(ខ) បម្រែបម្រួលនៃការងារ ការទាមទារនានា និងការចំណាយលើកទឹកចិត្តតាមកិច្ចសន្យា :

ក- ក្នុងពេលដែលមានភាពប្រាកដប្រជាថា បម្រែបម្រួលទាំងនោះ អាចនាំឲ្យមានចំណូល

ខ- បម្រែបម្រួលទាំងនោះ អាចត្រូវបានវាស់វែងប្រកបដោយការទុកចិត្តបាន ។

១២ ចំណូលពីកិច្ចសន្យា ត្រូវបានវាស់វែងតាមតម្លៃទីផ្សារនៃប្រាក់ចំណូល (តម្លៃតបស្នង)ដែលបានទទួលឬដែលនឹងអាចទទួលបាន។ការវាស់វែងចំណូលពីកិច្ចសន្យា ត្រូវបានទទួលឥទ្ធិពលពីភាពមិនប្រាកដប្រជាជាច្រើនដែលអាស្រ័យលើទិន្នផលនៃព្រឹត្តិការណ៍នាពេលអនាគត ។ ការប៉ាន់ស្មានជារឿយៗ ត្រូវការសើរើនៅពេលដែលព្រឹត្តិការណ៍បានកើតឡើងនិងពេលដែលភាពមិនប្រាកដប្រជាត្រូវបានដោះស្រាយ ។ ដូចនេះ ហើយបរិមាណទឹកប្រាក់ចំណូលពីកិច្ចសន្យាអាចកើនឡើងឬ ថយចុះពីការិយបរិច្ឆេទមួយ ទៅការិយបរិច្ឆេទមួយទៀត។ ឧទាហរណ៍ដូចជា :

(ក) អ្នកសាងសង់ និងអតិថិជនយល់ព្រមលើបម្រែបម្រួលឬការទាមទារដែលបង្កើនឬបន្ថយចំណូលតាមកិច្ចសន្យាក្នុងការិយ-បរិច្ឆេទមួយបន្តបន្ទាប់ ចាប់ពីកិច្ចសន្យាត្រូវបានព្រមព្រៀងភ្លាម ។

(ខ) បរិមាណទឹកប្រាក់ចំណូលដែលបានព្រមព្រៀងតាមកិច្ចសន្យាថ្លៃថេរអាចកើនឡើងដោយសារតែមានចែងអំពីខនៃការបង្កើនថ្លៃដើម ។

(គ) ចំនួនទឹកប្រាក់ចំណូលពីកិច្ចសន្យា អាចថយចុះដោយសារតែការផាកពិន័យដែលបណ្តាលមកពីការពន្យាពេលក្នុងការអនុវត្តកិច្ចសន្យាដោយអ្នកសាងសង់ ឬ

(ឃ) ចំណូលតាមកិច្ចសន្យាកើនឡើង ដោយសារចំនួនឯកតាបានកើនឡើងនៅពេលដែលកិច្ចសន្យាថ្លៃថេរ ពាក់ព័ន្ធនឹងថ្លៃថេរក្នុងមួយឯកតាទិន្នផល។

១៣ បម្រែបម្រួល គឺជាការស្នើចង់បានរបស់អតិថិជនចំពោះការប្រែប្រួលនៃទំហំការងារដែលត្រូវបំពេញតាមកិច្ចសន្យា ។ បម្រែបម្រួលអាចនាំឲ្យចំណូលពីកិច្ចសន្យាមានការកើនឡើងឬថយចុះ ។ ឧទាហរណ៍ដែលបង្ហាញអំពីបម្រែបម្រួល គឺជាការប្រែប្រួលលើលក្ខណៈពិសេស ឬការតុបតែងរបស់ទ្រព្យសកម្ម និងការប្រែប្រួលលើពេលវេលាអនុវត្តកិច្ចសន្យា ។ បម្រែបម្រួលត្រូវបានបញ្ចូលក្នុងចំណូលតាមកិច្ចសន្យានៅពេលដែល :

(ក) វាមានភាពប្រាកដថា អតិថិជននឹងទទួលយកនូវបម្រែបម្រួលនោះ ហើយទឹកប្រាក់នៃចំណូលដែលកើតពីបម្រែបម្រួលនោះ និង

(ខ) ចំនួនទឹកប្រាក់នៃចំណូលអាចត្រូវបានវាស់វែងដោយទុកចិត្ត។

១៤ ការទាមទារ គឺជាចំនួនដែលអ្នកសាងសង់ស្វះស្វែងប្រមូលពីអតិថិជនឬពីភាគីផ្សេងទៀត ជាសំណងទូទាត់ថ្លៃដើមដែលមិនបានបញ្ចូលនៅក្នុងថ្លៃកិច្ចសន្យា ។ ឧទាហរណ៍ ការទាមទារអាចកើតពីការពន្យានានាដែលធ្វើឡើងដោយអតិថិជន ការភ័ន្តច្រឡំលើលក្ខណៈពិសេសឬ ការតុបតែង និងបម្រែបម្រួលនៃការងារតាមកិច្ចសន្យា ដែលបានកើតមានជម្លោះ ។ ការវាស់វែងបរិមាណទឹកប្រាក់ចំណូលដែលកើតពីការទាមទារ គឺជាកម្មវត្ថុនៃភាពមិនប្រាកដប្រជាដែលមានកម្រិតខ្ពស់ ហើយ

ជារឿយៗ វាអាស្រ័យលើលទ្ធផលនៃការចរចារ។ដូចនេះ ការទាមទារត្រូវបានបញ្ចូលនៅក្នុងចំណូលតាមកិច្ចសន្យាតែនៅពេលដែល :

(ក) ការចរចារសម្រេចបានដល់ដំណាក់កាលមួយដែលថាអតិថិ-ជនប្រហែលជានឹងទទួលយកនូវការទាមទារនោះ និង

(ខ) ចំនួនទឹកប្រាក់ដែលប្រហែលជាអាចទទួលយកដោយអតិថិ-ជន អាចវាស់វែងបានប្រកបដោយការទុកចិត្ត។

១៥ ការចំណាយទៅលើការលើកទឹកចិត្តគឺជាចំនួនទឹកប្រាក់បន្ថែមដែលត្រូវបង់ឲ្យអ្នកសាងសង់ ប្រសិនបើអ្នកសាងសង់ ធ្វើបានតាមស្តង់ដារនៃកិច្ចប្រតិបត្តិដែលបានចែង ឬលើសពីស្តង់ដារនោះ ។ ឧទាហរណ៍ កិច្ចសន្យាមួយអាចអនុញ្ញាតឲ្យមានការទូទាត់ប្រាក់លើកទឹកចិត្តដល់អ្នកសាងសង់នៅពេលដែលបំពេញកិច្ចសន្យាមុនកាលកំណត់ ។ ការទូទាត់ប្រាក់លើកទឹកចិត្ត ត្រូវបានបញ្ចូលក្នុងចំណូលតាមកិច្ចសន្យា នៅពេលដែល :

(ក) កិច្ចសន្យាមានការវិវឌ្ឍទៅមុខគ្រប់គ្រាន់ដែលអាចបំពេញបានតាមស្តង់ដារនៃកិច្ចប្រតិបត្តិដែលបានចែង ឬលើសពីស្តង់ដារនោះ និង

(ខ) ចំនួនទឹកប្រាក់នៃការទូតាត់ប្រាក់លើកទឹកចិត្ត អាចវាស់វែងបានប្រកបដោយការទុកចិត្ត។

## ថ្លៃដើមតាមកិច្ចសន្យា

១៦ ថ្លៃដើមតាមកិច្ចសន្យា ត្រូវមាន :

(ក) ថ្លៃដើមដែលទាក់ទិនដោយផ្ទាល់ទៅនឹងកិច្ចសន្យាជាជាកំណត់។

(ខ) ថ្លៃដើមដែលអាចមានចំពោះសកម្មភាពនានាក្នុងកិច្ចសន្យាជាទូទៅ និងអាចធ្វើវិភាជន៍ដល់កិច្ចសន្យា និង

(គ) ថ្លៃដើមដទៃទៀតដែលអាចយកជាពិសេសពីអតិថិជនតាមលក្ខខណ្ឌក្នុងកិច្ចសន្យា។

១៧ ថ្លៃដើមដែលទាក់ទិនដោយផ្ទាល់ជាមួយកិច្ចសន្យាជាកំណត់មួយរួមមាន:

(ក) ថ្លៃដើមពលកម្មនៅការដ្ឋាន រួមទាំងការគ្រប់គ្រងការដ្ឋាន

(ខ) ថ្លៃដើមសម្ភារៈដែលបានប្រើប្រាស់ក្នុងការសាងសង់។

(គ) ចំណាយដករំលោះលើរោងចក្រនិងសម្ភារៈបរិក្ខាដែលបានប្រើប្រាស់តាមកិច្ចសន្យា។

(ឃ) ថ្លៃដើមនៃការចល័តរោងចក្រ បរិក្ខា និងសម្ភារៈនានាទៅនឹងមកពីការដ្ឋានតាមកិច្ចសន្យា។

(ង) ថ្លៃដើមជួលរោងចក្រនិងបរិក្ខា។

(ច) ថ្លៃដើមតុបតែងនិងជំនួយបច្ចេកទេសដែលតាក់ទងដោយផ្ទាល់ទៅនឹងកិច្ចសន្យា ។

(ឆ) ថ្លៃដើមប៉ាន់ស្មានលើការកែតម្រូវនិងការធានាចំពោះការងាររួមទាំងថ្លៃដើមធានាដែលរំពឹងទុក និង

(ជ) ការទាមទារពីភាគីទីបី ។

ថ្លៃដើមទាំងអស់នេះ អាចត្រូវបានកាត់បន្ថយជាមួយប្រាក់ចំណូលដែលបានទទួលដោយចៃដន្យ ដែលមិនបានបញ្ចូលនៅក្នុងចំណូលតាមកិច្ចសន្យា ឧទាហរណ៍ដូចជា ចំណូលពីការលក់សម្ភារៈដែលលើសពីការប្រើប្រាស់ និងការលក់បញ្ចេញចោលនៃរោងចក្រនិងបរិក្ខានាពេលបញ្ចប់កិច្ចសន្យា។

១៨ ជាទូទៅថ្លៃដើមដែលអាចមានចំពោះសកម្មភាពតាមកិច្ចសន្យា និងអាចត្រូវបានធ្វើវិភាជន៍ដល់កិច្ចសន្យានានាជាកំណត់ រួមមាន :

(ក) ធានារ៉ាប់រង។

(ខ) ថ្លៃដើមតុបតែងនិងជំនួយបច្ចេកទេស ដែលមិនទាក់ទិនដោយផ្ទាល់ជាមួយនឹងកិច្ចសន្យាដោយឡែក និង

(គ) ចំណាយបន្ទាប់បន្សំក្នុងការសាងសង់។

ថ្លៃដើមបែបនេះត្រូវបានធ្វើវិភាជន៍ដោយប្រើវិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធនិងសមហេតុផលព្រមទាំងត្រូវបានអនុវត្តដោយអនុលោមភាពទៅនឹងថ្លៃដើមទាំងអស់ដែលមានចរិកលក្ខណៈស្រដៀងគ្នា។ ការធ្វើវិភាជន៍ត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃកម្រិតសកម្ម-

ភាពសាងសង់ជាធម្មតា ។ ចំណាយបន្ទាប់បន្សំសម្រាប់ការសាង សង់រួមមានថ្លៃដើមដូចជាការរៀបចំនិងដំណើរការរៀបចំបៀវត្សរបស់បុគ្គលិកសាងសង់ ។ ជាទូទៅថ្លៃដើមដែលអាចមានចំពោះសកម្មភាពតាមកិច្ចសន្យានិងដែលអាចធ្វើវិភាជន៍ដល់កិច្ចសន្យាជាកំណត់ ក៏រាប់បញ្ចូលផងដែរនូវបន្ទុកនៃប្រាក់កម្ចី ។

១៩ ថ្លៃដើមដែលអាចយកជាពិសេសពីអតិថិជនតាមលក្ខខណ្ឌនៃកិច្ចសន្យាអាចរាប់បញ្ចូលនូវថ្លៃដើមរដ្ឋបាលទូទៅនិងថ្លៃដើមអភិវឌ្ឍ ដែលការទូទាត់អាចត្រូវបានចែងជាពិសេសតាមលក្ខខណ្ឌនៃកិច្ចសន្យា ។

២០ ថ្លៃដើមដែលមិនអាចមានចំពោះសកម្មភាពនៃកិច្ចសន្យា ឬដែលមិនអាចត្រូវបានធ្វើវិភាជន៍ចំពោះកិច្ចសន្យាមួយ អាចត្រូវបានដកចេញពីថ្លៃដើមនៃកិច្ចសន្យាសាងសង់។ ថ្លៃដើមបែបនេះរួមមាន :

(ក) ថ្លៃដើមរដ្ឋបាលទូទៅ ដែលការទូទាត់មិនបានចែងនៅក្នុងកិច្ចសន្យា ។

(ខ) ថ្លៃដើមលក់ ។

(គ) ថ្លៃដើមស្រាវជ្រាវនិងអភិវឌ្ឍ ដែលការទូទាត់មិនបានចែងនៅក្នុងកិច្ចសន្យានិង

(ឃ) ចំណាយរំលោះនៃរោងចក្រនិងបរិក្ខាដែលមិនដំណើរការ ដែលមិនត្រូវបានប្រើប្រាស់តាមកិច្ចសន្យាជាពិសេសមួយ ។

២១ ថ្លៃដើមកិច្ចសន្យារួមមានថ្លៃដើមដែលកើតមានចំពោះកិច្ចសន្យាសម្រាប់ការិយបរិច្ឆេទចាប់ពីកាលបរិច្ឆេទចាប់ផ្តើមធ្វើកិច្ចសន្យារហូតដល់បញ្ចប់កិច្ចសន្យា ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ថ្លៃដើមដែលទាក់ទិនដោយផ្ទាល់ទៅនឹងកិច្ចសន្យាមួយ ហើយដែលបានកើតឡើងក្នុងការអនុវត្តកិច្ចសន្យា ក៏ត្រូវបានបញ្ចូលជាផ្នែកមួយនៃថ្លៃដើមកិច្ចសន្យា ប្រសិនបើថ្លៃដើមទាំងនោះ អាចត្រូវបានកំណត់ដាច់ដោយឡែកនិងអាចវាស់វែងប្រកបដោយការទុកចិត្តហើយវាប្រហែលថា នឹងទទួលបាននូវកិច្ចសន្យា ។ នៅពេលថ្លៃដើមបានកើតឡើងដើម្បីអនុវត្តកិច្ច-សន្យាមួយ ដែលតម្រូវបានទទួលស្គាល់ថាជាចំណាយមួយក្នុងការិយ-

បរិច្ឆេទ ដែលថ្លៃដើមនោះបានកើតមានថ្លៃដើមទាំងនោះមិនត្រូវបានបញ្ចូលក្នុងថ្លៃដើមកិច្ចសន្យានៅពេលដែលកិច្ចសន្យាត្រូវបានទទួលក្នុងការិយបរិច្ឆេទបន្តបន្ទាប់ ។

## ការទទួលស្គាល់ចំណូលនិងចំណាយតាមកិច្ចសន្យា

២២ នៅពេលដែលចំណូលនៃកិច្ចសន្យាសាងសង់អាចត្រូវបានប៉ាន់ស្មានប្រកបដោយទុកចិត្តចំណូលពីកិច្ចសន្យានិងថ្លៃដើមតាមកិច្ចសន្យាដែលមានជាប់ជាមួយកិច្ចសន្យាសាងសង់ ត្រូវតែបានទទួលស្គាល់ថាជាចំណូល និងចំណាយ ដោយផ្អែកលើដំណាក់កាលនៃការបំពេញសកម្មភាពតាមកិច្ចសន្យានាចុងការិយបរិច្ឆេទរាយការណ៍ ។ ការខាតបង់ដែលបានរំពឹងទុកពីកិច្ចសន្យាសាងសង់ត្រូវតែបានទទួលស្គាល់ថាជាចំណាយ ភ្លាមស្របតាមកថាខណ្ឌ ៣៦ ។

២៣ ក្នុងករណីដែលកិច្ចសន្យាមួយជាកិច្ចសន្យាថ្លៃថេរ ចំណូលពីកិច្ចសន្យាសាងសង់ អាចត្រូវបានប៉ាន់ស្មានគួរឲ្យទុកចិត្តនៅពេលដែលបំពេញបាន តាមលក្ខខណ្ឌទាំងអស់ដូចខាងក្រោម :

(ក) ចំណូលតាមកិច្ចសន្យាសរុបអាចត្រូវបានវាស់វែងប្រកបដោយការទុកចិត្ត។

(ខ) វាប្រហែលជាអត្ថប្រយោជន៍សេដ្ឋកិច្ចដែលមានជាប់ជាមួយកិច្ចសន្យា នឹងហូរចូលអង្គភាព។

(គ) ទាំងថ្លៃដើមតាមកិច្ចសន្យាដើម្បីអនុវត្តកិច្ចសន្យា និងទាំងដំណាក់កាលនៃការបំពេញកិច្ចសន្យានាចុងការិយបរិច្ឆេទរាយការណ៍ អាចត្រូវបានវាស់វែងប្រកបដោយការទុកចិត្ត និង

(ឃ) ថ្លៃដើមតាមកិច្ចសន្យាដែលអាចមានចំពោះកិច្ចសន្យាអាចត្រូវបានបញ្ជាក់និង វាស់វែងប្រកបដោយការទុកចិត្ត ដូចនេះថ្លៃដើមតាមកិច្ចសន្យាជាក់ស្តែងដែលបានកើតឡើងអាចប្រៀបធៀបបានជាមួយការប៉ាន់ស្មានដែលបានធ្វើឡើងមុនៗ ។

២៤ ក្នុងករណីដែលមានកិច្ចសន្យាដែលបន្ថែមថ្លៃដើម ទិន្នផលនៃកិច្ចសន្យាសាងសង់ អាចត្រូវបានប៉ាន់ស្មានយ៉ាងត្រឹមត្រូវ នៅពេលដែលលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានបំពេញ :

(ក) វាប្រហែលជាមានអត្ថប្រយោជន៍សេដ្ឋកិច្ចដែលមានជាប់ជាមួយកិច្ចសន្យា នឹងហូរចូលអង្គភាព និង

(ខ) ថ្លៃដើមតាមកិច្ចសន្យាដែលអាចមានលើកិច្ចសន្យា ទោះបីជាវាអាចទូទាត់ជាពិសេសឬមិនអាចទូទាត់ក៏ដោយថ្លៃដើមទាំងនោះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ និងអាចត្រូវបានវាស់វែងដែលគួរឲ្យទុកចិត្តបាន។

២៥ ការទទួលស្គាល់នូវចំណូលនិងចំណាយ ដោយផ្អែកតាមដំណាក់កាលនៃការបំពេញកិច្ចសន្យាមួយ គឺតែងតែសំដៅដល់ភាគរយនៃវិធិសាស្រ្តអនុវត្តកិច្ចសន្យា ។ តាមវិធីសាស្រ្តនេះចំណូលពីកិច្ចសន្យាត្រូវបានផ្គូរផ្គងជាមួយថ្លៃដើមតាមកិច្ចសន្យាដែលបានកើតឡើង ដើម្បីសម្រេចបាននូវដំនាក់កាលនៃការអនុវត្ត ហើយត្រូវរាយការណ៍អំពីចំណូលចំណាយ និងប្រាក់ចំណេញ ដែលអាចមានទៅតាមសមាមាត្រនៃការងារដែលបានបំពេញ ។ វិធីសាស្រ្តនេះផ្តល់នូវព័ត៌មានដែលមានប្រយោជន៍អំពីសកម្មភាព និងកិច្ចប្រតិបត្តិកិច្ចសន្យាក្នុងកំឡុងការិយបរិច្ឆេទ។

២៦ តាមអត្រាភាគរយនៃវិធីសាស្រ្តបំពេញការងារចំណូលពីកិច្ចសន្យា ត្រូវបានទទួលស្គាល់ថាជាចំណូលនៅក្នុងចំណេញឬខាត ក្នុងការិយបរិច្ឆេទគណនេយ្យដែលការងារត្រូវបានបំពេញ ។ ថ្លៃដើមតាមកិច្ចសន្យាជាធម្មតាត្រូវបានទទួលស្គាល់ថាជាចំណាយនៅក្នុងចំណេញឬខាតក្នុងការិយបរិច្ឆេទគណនេយ្យដែលការងារពាក់ព័ន្ធត្រូវបានបំពេញ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយរាល់ភាពលើសដែលបានរំពឹងទុកនៃថ្លៃដើមតាមកិច្ចសន្យាសរុប ច្រើនជាងចំណូលសរុបពីកិច្ចសន្យា ត្រូវបានទទួលស្គាល់ថាជាចំណាយភ្លាមស្របតាមកថាខណ្ឌ ៣៦ ។

២៧ អ្នកសាងសង់ អាចបង្កើតឱ្យមានថ្លៃដើមតាមកិច្ចសន្យាដែលទាក់ទិន នឹងសកម្មភាពនាពេលអនាគតតាមកិច្ចសន្យា ។ ថ្លៃដើមតាមកិច្ចសន្យា បែបនេះ ត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មមួយ ដែលបានផ្តល់នូវ ព័ត៌មានថាវាប្រហែលជានឹងទទួលបានថ្លៃដើមនោះមកវិញ ។ ថ្លៃដើម ទាំងនេះ តំណាងឱ្យចំនួនទឹកប្រាក់បំណុលដែលទទួលពីអតិថិជន និង តែងតែត្រូវបានចាត់ថ្នាក់ថាជាការងារតាមកិច្ចសន្យាកំពុងដំណើរការ ។

២៨ ទិន្នផលនៃកិច្ចសន្យាសាងសង់ អាចប៉ាន់ស្មានគួរឱ្យទុកចិត្តបានតែនៅ ពេលដែលវាប្រហែលជាមានអត្ថប្រយោជន៍សេដ្ឋកិច្ចដែលមានជាប់ជា មួយកិច្ចសន្យានឹងហូរចូលទៅក្នុងអង្គភាព ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ ដោយនៅពេលដែលភាពមិនប្រាកដប្រជា កើតមានពាក់ព័ន្ធនឹងលទ្ធ-ភាពនៃការប្រមូលចំនួនទឹកប្រាក់ដែលបានបញ្ចូលរួចរាល់ជាចំណូលនៃ កិច្ចសន្យា ហើយក៏បានទទួលស្គាល់រួចរាល់ក្នុងចំណេញឬខាតទឹកប្រាក់ ដែលមិនអាចប្រមូលបាន ឬទឹកប្រាក់ដែល ត្រូវទទួលត្រឡប់មកវិញ ប្រហែលជានឹងមិនកើតមានត្រូវបានគេទទួល ស្គាល់ជាចំណាយជាជាង ត្រូវបានទទួលស្គាល់ជាការកែសម្រួលទឹក ប្រាក់ចំណូលកិច្ចសន្យា ។

២៩ ជាទូទៅ អង្គភាពអាចធ្វើការប៉ាន់ស្មានគួរឱ្យទុកចិត្ត បន្ទាប់ពីបានព្រម ព្រៀងលើកិច្ចសន្យា ដែលបង្កើតឡើងនូវ :

(ក) សិទ្ធិអាចចាប់បង្ខំបានរបស់ភាគីនិមួយៗ ទៅលើទ្រព្យសកម្ម ដែលនឹងត្រូវសាងសង់ ។

(ខ) តម្លៃតបស្នងដែលត្រូវដោះដូរ និង

(គ) លក្ខណៈ និងលក្ខខណ្ឌនៃការទូទាត់ ។

ជាធម្មតា វាក៏មានការចាំបាច់ផងដែរសម្រាប់អង្គភាព ក្នុងការឱ្យមាន ប្រព័ន្ធធ្វើគម្រោងថវិកានិងប្រព័ន្ធរាយការណ៍ផ្ទៃក្នុងដ៏មានប្រសិទ្ធភាព។ នៅពេលមានការចាំបាច់ អង្គភាពពិនិត្យឡើងវិញ និងសើរើលើការ ប៉ាន់ស្មាននានាលើចំណូលនៃកិច្ចសន្យា និងថ្លៃដើមតាមកិច្ចសន្យាតាម ការវិវត្តនៃកិច្ចសន្យា ។ តម្រូវការនៃការសើរើនេះ មិនចាំបាច់បង្ហាញថា ទិន្នផលនៃកិច្ចសន្យា មិនអាចត្រូវបានប៉ាន់ស្មានគួរឱ្យទុកចិត្តនោះទេ ។

៣០ ដំណាក់កាលនៃការបំពេញកិច្ចសន្យាអាចត្រូវបានកំណត់តាមមធ្យោបាយជាច្រើន។ អង្គភាពប្រើប្រាស់វិធីសាស្ត្រដែលវាស់វែងគួរឱ្យទុកចិត្តលើការងារដែលបានបំពេញរួច ។ ដោយផ្អែកតាមចរិលក្ខណៈនៃកិច្ចសន្យាវិធីសាស្ត្ររួមមាន :

(ក) សមាមាត្រដែលថ្លៃដើមតាមកិច្ចសន្យាបានកើតឡើងលើការងារដែលបានបំពេញ ធៀបនឹងថ្លៃដើមកិច្ចសន្យាប៉ាន់ស្មានសរុបត្រឹមកាលបរិច្ឆេទបិទបញ្ជី ។

(ខ) ការអង្កេតលើការងារដែលបានបំពេញ ឬ

(គ) ការបំពេញនូវសមាមាត្រជារូបវន្តនៃការងារតាមកិច្ចសន្យា។

ការទូទាត់តាមការវិវត្ត និងប្រាក់បុរេប្រទានដែលទទួលបានពីអតិថិជនតែងតែមិនបង្ហាញអំពីការងារដែលបានបំពេញនោះទេ ។

៣១ នៅពេលដែលដំណាក់កាលនៃការបំពេញការងារត្រូវបានកំណត់ដោយយោងលើថ្លៃដើមតាមកិច្ចសន្យាដែលបានកើតឡើងរហូតមកដល់ពេលបច្ចុប្បន្ន មានតែថ្លៃដើមតាមកិច្ចសន្យាទាំងនោះទេ ដែលបង្ហាញថាការងារដែលបានបំពេញត្រូវបានបញ្ចូលក្នុងថ្លៃដើមដែលកើតឡើងនាពេលបច្ចុប្បន្ន ។ ឧទាហរណ៍នៃថ្លៃដើមតាមកិច្ចសន្យាដែលបានដកចេញរួមមាន :

(ក) ថ្លៃដើមកិច្ចសន្យាដែលទាក់ទិននឹងសកម្មភាពនាពេលអនាគតនៅក្នុងកិច្ចសន្យា ដូចជាថ្លៃដើមសម្ភារៈដែលត្រូវបានផ្តល់ដល់កន្លែងអនុវត្តកិច្ចសន្យា ឬដែលកំណត់ដោយឡែកសម្រាប់ប្រើប្រាស់ក្នុងកិច្ចសន្យា ប៉ុន្តែមិនទាន់បានតម្លើងប្រើប្រាស់ ឬអនុវត្តក្នុងកំឡុងពេលប្រតិបត្តិកិច្ចសន្យានៅឡើយ វាលែងតែសម្ភារៈទាំងនោះត្រូវបានទិញជាពិសេសសម្រាប់កិច្ចសន្យានិង

(ខ) ការទូទាត់ដែលបានធ្វើឡើងចំពោះអ្នកម៉ៅការបន្ត មុននឹងការងារត្រូវបានបំពេញ តាមកិច្ចសន្យារង ។

៣២ នៅពេលដែលទិន្នផលពីកិច្ចសន្យាសាងសង់មិនអាចត្រូវបានប៉ាន់ស្មានគួរឱ្យទុកចិត្តនោះទេ :

(ក) ចំណូលត្រូវបានទទួលស្គាល់តែក្នុងករណីដែលថ្លៃដើមតាមកិច្ចសន្យាបានកើតឡើងហើយដែលប្រហែលជានឹងទទួលបានថ្លៃដើមនោះត្រឡប់មកវិញ និង

(ខ) ថ្លៃដើមកិច្ចសន្យាត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងការិយ-បរិច្ឆេទដែលថ្លៃដើមបានកើតឡើង ។

ការខាតបង់ដែលបានរំពឹងទុកពីកិច្ចសន្យាសាងសង់ ត្រូវបានទទួលស្គាល់ថាជាចំណាយមួយភ្លាមៗ ស្របតាមកថាខណ្ឌ ៣៦ ។

៣៣ ក្នុងកំឡុងដំណាក់កាលដំបូងនៃកិច្ចសន្យា តែងតែមានករណីដែលទិន្ន-ផលនៃកិច្ចសន្យានោះ មិនអាចត្រូវបានប៉ាន់ស្មានគួរឲ្យទុកចិត្តបាន។ ទោះជាយ៉ាងណាក៏ដោយ វាប្រហែលជាថាអង្គភាពនឹងទទួលបានមកវិញនូវថ្លៃដើមតាមកិច្ចសន្យាដែលបានកើតឡើង ។ ដូចនេះ ចំណូលពីកិច្ចសន្យាត្រូវបានទទួលស្គាល់តែក្នុងករណីដែលថ្លៃដើមដែលបានកើតឡើងត្រូវបានរំពឹងថានឹងទទួលបានមកវិញ ។ ករណីដែលទិន្នផលពីកិច្ចសន្យាមិនអាចប៉ាន់ស្មានប្រកបដោយទុកចិត្តបានគ្មានប្រាក់ចំណេញណាត្រូវបានទទួលស្គាល់នោះទេ ។ ប៉ុន្តែទោះបីជាទិន្នផលពីកិច្ចសន្យាមិនអាចត្រូវបានប៉ាន់ស្មានគួរឲ្យទុកចិត្តយ៉ាងណាក៏ដោយ វាប្រហែលថាថ្លៃដើមកិច្ចសន្យាសរុប នឹងលើសពីចំណូលពីកិច្ចសន្យាសរុប ។ ក្នុងករណីនេះ ថ្លៃដើមសរុបនៃកិច្ចសន្យាដែលរំពឹងទុកថានឹងលើសចំណូលពីកិច្ចសន្យាសរុប ត្រូវបានទទួលស្គាល់ថាជាចំណាយភ្លាមៗ ស្របតាមកថាខណ្ឌ ៣៦ ។

៣៤ ថ្លៃដើមតាមកិច្ចសន្យា ដែលប្រហែលជាមិនអាចទទួលបានមកវិញ ត្រូវបាទទួលស្គាល់ថាជាចំណាយភ្លាមៗ ។ ឧទាហរណ៍នៃកាលទេសៈដែលភាពអាចទទួលបានមកវិញនូវថ្លៃដើមតាមកិច្ចសន្យាដែលបានចំណាយប្រហែលជាមិនអាចកើតមាន និងដែលថ្លៃដើមតាមកិច្ចសន្យាអាចត្រូវការទទួលស្គាល់ជាចំណាយត្រូវបានទទួលស្គាល់ភ្លាមៗរួមមានកិច្ចសន្យា :

(ក) ដែលមិនអាចអនុវត្តបានយ៉ាងពេញលេញ ដូចជា ករណីសុ-ពលភាពរបស់វាមានបញ្ហាធ្ងន់ធ្ងរ ។

(ខ) ដែលការបំពេញកិច្ចសន្យានោះ ជាកម្មវត្ថុនៃទិន្នផលនៃជម្លោះ ឬបញ្ហាខាងផ្លូវច្បាប់ដែលមិនទាន់ដោះស្រាយរួច ។

(គ) ដែលទាក់ទិនទៅនឹងកម្មសិទ្ធិដែលប្រែហលជានឹងទទួលទណ្ឌ-កម្ម ឬធ្វើអសាមិករណ៍

(ឃ) ដែលអតិថិជនមិនអាចបំពេញតាមលក្ខខណ្ឌរបស់កិច្ចសន្យាបាន ឬ

(ង) ដែលអ្នកសាងសង់មិនអាចបំពេញកិច្ចសន្យាឬក៏មិនអាចបំពេញកាតព្វកិច្ចតាមកិច្ចសន្យាបាន។

៣៥ នៅពេលដែលភាពមិនប្រាកដប្រជាដែលបានរាំងមិនឲ្យទិន្នផលនៃកិច្ចសន្យាដែលបានប៉ាន់ស្មានគួរឲ្យទុកចិត្តនោះ លែងមានតទៅទៀត ចំណូលនិងចំណាយដែលមានភ្ជាប់មកជាមួយកិច្ចសន្យាសាងសង់ត្រូវតែបានទទួលស្គាល់ ស្របតាមកថាខណ្ឌ ២២ ជាជាងតាមកថាខណ្ឌ ៣២ ។

## ការទទួលស្គាល់ការខាតបង់ដែលបានរំពឹងទុក

៣៦ នៅពេលដែលវាប្រហែលជាថា ថ្លៃដើមតាមកិច្ចសន្យាសរុប នឹងមានចំនួនលើសពីចំណូលតាមកិច្ចសន្យាកាតខាតបង់ដែលបានរំពឹងទុកត្រូវតែបានទទួលស្គាល់ជាចំណាយភ្លាមៗ។

៣៧ ចំនួនទឹកប្រាក់នៃការខាតបង់បែបនេះ ត្រូវបានទទួលស្គាល់មិនមានដែនកំណត់នូវ :

(ក) ថាតើកិច្ចសន្យា បានចាប់ផ្តើមតាមកិច្ចសន្យាឬទេ។

(ខ) ដំណាក់កាលនៃការបំពេញសកម្មភាពកិច្ចសន្យា ឬ

(គ) ចំនួនទឹកប្រាក់ចំណេញដែលបានរំពឹងទុកថានឹងកើតមានពីកិច្ចសន្យាដទៃទៀត ដែលមិនបានចាត់ទុកថាជាកិច្ចសន្យាសាងសង់តែមួយ ស្របតាមកថាខណ្ឌ ៩ ។

## ការប្រែប្រួលលើការប៉ាន់ស្មាន

៣៨ អត្រាភាគរយនៃវិធីសាស្ត្របំពេញការងារ ត្រូវបានអនុវត្តដោយឈរលើមូលដ្ឋានបូកយោងក្នុងការិយបរិច្ឆេទគណនេយ្យនីមួយៗចំពោះការប៉ាន់ស្មានជាក់ស្តែងលើចំណូលពីកិច្ចសន្យានិងថ្លៃដើមតាមកិច្ចសន្យា ។ ដូចនេះ ឥទ្ធិពលនៃការប្រែប្រួលលើការប៉ាន់ស្មានចំណូលពីកិច្ចសន្យា ឬថ្លៃដើមចំណាយតាមកិច្ចសន្យា ឬឥទ្ធិពលនៃការប្រែប្រួលលើការប៉ាន់ស្មានលើទិន្នផលនៃកិច្ចសន្យា ត្រូវបានចាត់ថាជាការប្រែប្រួលនៃការប៉ាន់ស្មានគណនេយ្យ (សូមមើលស្តង់ដារគណនេយ្យអន្តរជាតិ ៨ ស្តីពី *គោលនយោបាយគណនេយ្យ ការប្រែប្រួលលើការប៉ាន់ស្មានគណនេយ្យ និងការភ័ន្តច្រឡំ* ) ។ ការប៉ាន់ស្មានដែលបានប្រែប្រួលត្រូវបានប្រើប្រាស់ សម្រាប់កំណត់បរិមាណទឹកប្រាក់ចំណូលនិងចំណាយដែលបានទទួលស្គាល់នៅក្នុងចំណេញឬខាតក្នុងការិយបរិច្ឆេទដែលការប្រែប្រួលបានកើតមាននិងក្នុងការិយបរិច្ឆេទបន្តបន្ទាប់ ។

## ការលាតត្រដាងព័ត៌មាន

៣៩ អង្គភាព ត្រូវលាតត្រដាងព័ត៌មាន :

(ក) ចំនួនទឹកប្រាក់នៃចំណូលតាមកិច្ចសន្យាដែលបានទទួលស្គាល់ថាជាចំណូលក្នុងការិយបរិច្ឆេទ ។

(ខ) វិធីសាស្ត្រដែលបានប្រើសម្រាប់កំណត់ចំណូល ពីកិច្ចសន្យាដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទ និង

(គ) វិធីសាស្ត្រដែលប្រើប្រាស់ដើម្បីកំណត់អំពីដំណាក់កាលនៃការបំពេញដំណើរការកិច្ចសន្យា ។

៤០ អង្គភាពត្រូវលាតត្រដាងអំពីចំណុចនីមួយៗខាងក្រោម សម្រាប់ដំណើរការកិច្ចសន្យានាចុងការិយបរិច្ឆេទរាយការណ៍ :

(ក) ចំនួនទឹកប្រាក់សរុបនៃថ្លៃដើមដែលបានកើតមានឡើងនិងចំនួនទឹកប្រាក់ចំណេញដែលបានទទួលស្គាល់រហូតមកដល់បច្ចុប្បន្ន (ដកការខាតបង់ដែលបានទទួល- ស្គាល់) ។

(ខ) ចំនួនទឹកប្រាក់បុរេប្រទានដែលទទួលបាន និង

(គ) ចំនួនទឹកប្រាក់ឃាត់ទុក ។

៤១ ទឹកប្រាក់ឃាត់ទុក គឺជាចំនួនទឹកប្រាក់លើវិក័យបត្រដែលមានជាបន្តបន្ទាប់ដែលមិនទាន់ត្រូវបានទូទាត់រហូតទាល់តែមានការទទួលយកនូវលក្ខខណ្ឌទូទាត់នានាដែលបានបញ្ជាក់ក្នុងកិច្ចសន្យា ឬរហូតទាល់តែវិការៈ(ការខ្វះចន្លោះ)នានាត្រូវបានកែតម្រូវរួច ។ វិក័យបត្រទាំងនោះ គឺជាចំនួនទឹកប្រាក់ដែលបានចេញវិក័យបត្រទូទាត់លើការងារ ដែលបានបំពេញហើយតាមកិច្ចសន្យាទោះបីជាវិក័យបត្រទាំងនោះ ត្រូវបានទូទាត់ ឬមិនទាន់បានទូទាត់ដោយអតិថិជនក៏ដោយ។បុរេប្រទាន គឺជាទឹកប្រាក់ដែលអ្នកសាងសង់ទទួលបាន បន្ទាប់ពីបានបំពេញនូវការងារមួយចំនួនពាក់ព័ន្ធនឹងកិច្ចសន្យា ។

៤២ អង្គភាពត្រូវបង្ហាញ :

(ក) ចំនួនទឹកប្រាក់សរុបដែលដល់ពេលដែលត្រូវទទួលពីអតិថិជនសម្រាប់ការងារសាងសង់ ថាជាទ្រព្យសកម្ម និង

(ខ) ចំនួនទឹកប្រាក់សរុបដែលដល់ពេលដែលត្រូវបង់ឲ្យអតិថិជនសម្រាប់ការងារសាងសង់ថាជាបំណុល។

៤៣ ចំនួនទឹកប្រាក់សរុបដែលដល់ពេលដែលត្រូវទទួលពីអតិថិជនសម្រាប់ការងារសាងសង់ គឺជាទឹកប្រាក់សរុបនៃ :

(ក) ថ្លៃដើមដែលបានចំណាយ បូកនឹងប្រាក់ចំណេញ រួចដក

(ខ) ចំនួនទឹកប្រាក់ខាតបង់ និងវិក័យបត្រដែលមានបន្តបន្ទាប់

សម្រាប់រាល់កិច្ចសន្យាទាំងអស់ដែលកំពុងដំណើរការហើយដែលថ្លៃដើមបានកើតឡើង បូកប្រាក់ចំណេញដែលបានទទួលស្គាល់ (ដកការខាតបង់ដែលបានទទួលស្គាល់ )លើសពីវិក័យបត្រដែលមានជាបន្តបន្ទាប់។

៤៤ ចំនួនទឹកប្រាក់សរុបដែលដល់ពេលដែលត្រូវបង់ឲ្យអតិថិជនសម្រាប់ការងារសាងសង់ គឺជាចំនួនសរុបនៃ :

(ក) ថ្លៃដើមដែលបានចំណាយ បូកនឹងប្រាក់ចំណេញ រួចដក

(ខ) ចំនួនទឹកប្រាក់ខាតបង់ និងវិក័យបត្រដែលមានបន្តបន្ទាប់

សម្រាប់រាល់កិច្ចសន្យាទាំងអស់ដែលកំពុងដំណើរការ ហើយដែលពីវិក័យបត្រដែលមានជាបន្តបន្ទាប់លើសថ្លៃដើមបានកើតឡើងបូកប្រាក់ចំណេញដែលបានទទួលស្គាល់ (ដកការខាតបង់ដែលបានទទួលស្គាល់) ។

៤៥ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីបំណុលយថាហេតុនិងទ្រព្យសកម្មយថាហេតុស្របតាម ស.គ.អ ៣៧ស្តីពី *សំវិធានធនបំណុលយថាហេតុនិងទ្រព្យសកម្មយថាហេតុ)* ។ បំណុលយថាហេតុ និងទ្រព្យ-សកម្មយថាហេតុអាចកើតមកពីធាតុនានានៃថ្លៃដើមសម្រាប់ការធានានាការទាមទារពិន័យ ឬការខាតបង់ដែលងាយកើតមាន ។

## កាលបរិច្ឆេទចូលជាធរមាន

៤៦ ស្តង់ដារនេះ ចូលជាធរមានសម្រាប់របាយការហិរញ្ញវត្ថុទាំងឡាយណាដែលចាប់ផ្តើម ឬបន្ទាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ១៩៩៥។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាស័យដ្ឋាន: ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល: info@naccambodia.gov.kh | គេហទំព័រ: www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ